# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០ .សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC) លើកទី៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

**ប្រការ១** : បង្កើត **គណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤** ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាប្រធាន

២- ឯកឧត្តម **ឃី តាំងលីម** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជាអនុប្រធាន

៣- ឯកឧត្តម **មិន ឃិន** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ជាសមាជិក

| | | | |
|---|---|---|---|
| ៤- ឯកឧត្តមនាយឧត្តមសេនីយ៍ | **ហុក ឡុងឌី** | អគ្គស្នងការនគរបាលជាតិ | ជាសមាជិក |
| ៥- ឯកឧត្តម | **អ៊ុច គឹមអន** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៦- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧- ឯកឧត្តម | **អ៊ូ ឌិហោត** | រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| ៨- ឯកឧត្តម | **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ៩- ឯកឧត្តម | **គីម ស៊ីថន** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាសមាជិកអចិន្ត្រៃយ៍ |
| ១០- ឯកឧត្តម | **ចាម ញ៉ារិទ្ធ** | អភិបាលខេត្តសៀមរាប | ជាសមាជិក |
| ១១- ឯកឧត្តមឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |
| ១២- ឯកឧត្តមឧត្តមសេនីយ៍ទោ | **ជា ម៉ន** | មេបញ្ជាការយោធភូមិភាគទី៤ | ជាសមាជិក |
| ១៣- ឯកឧត្តម | **ហ៊ូ តាំងអេង** | អគ្គនាយកក្រសួងផែនការ | ជាសមាជិក |

**ប្រការ២ :** គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក-រៀបចំខ្លឹមសារ និងឯកសារប្រជុំដាក់ឆ្លងយោបល់គណៈរដ្ឋមន្ត្រី

ខ-រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

គ- រៀបចំគំរោងចំណាយសំរាប់រៀបចំកិច្ចប្រជុំនេះ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

ឃ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ

ង- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ច- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទេសចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ឆ- សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះជូនប្រមុខរាជរដ្ឋាភិបាល

ជ-រាយការណ៍ជាបន្តបន្ទាប់អំពីការចាត់ចែង និងសុំយោបល់ប្រមុខរាជរដ្ឋាភិបាលលើខ្លឹមសាររបស់អង្គប្រជុំក្នុងករណីដែលមានការប្រែប្រួល ។

**ប្រការ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៤ :** គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ៥ :** គណៈកម្មការនេះមានសិទ្ធិ ប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវរំសាយជាស្វ័យប្រវត្តិ បន្ទាប់ពីចប់ភារកិច្ច ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងដែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ និងឯកឧត្ដម ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ចម ប្រសិទ្ធ**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ